**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៦១)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 17-Sep-2019, 14:13
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

សូ មូស្សេឌ្នី
Suzana TOMANOVIĆ

**<u>ផ្ញើជូន៖</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហ្វួត វុទ្ធី

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

ចៅក្រមបម្រុង Steven J. BWANA

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS (បម្រុង)

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

តាមរយៈសហមេធាវីការពារក្តីរបស់គាត់ ("មេធាវីការពារក្តី") លោក យឹម ទិត្យ សូមដាក់*សំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ* ស្របតាមវិធាន ២១, ៣៩(៤) និង ៧៥(៣) នៃវិធានផ្ទៃក្នុង ("វិធាន") និងមាត្រា ៥(៤) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្ត")។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយ ("ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ") តែជាភាសាខ្មែរប៉ុណ្ណោះ[1]។ ឯកសារនេះមានកម្រាស់ ៥៦៦ ទំព័រ រួមទាំងឧបសម្ព័ន្ធផង។

២. នៅថ្ងៃដដែលនេះដែរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយ ("ដីកាដំណោះស្រាយរបស់ ស.ច.ស.អ") តែជាភាសាអង់គ្លេសប៉ុណ្ណោះ[2]។ អត្ថបទជាភាសាអង់គ្លេសនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ មានចំនួន ៤៨៧ ទំព័រ រួមទាំងឧបសម្ព័ន្ធផង។

៣. មេធាវីការពារក្តីបានទទួលសំណៅបកប្រែជាភាសាខ្មែរ នៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩។ សំណៅបកប្រែនេះមានចំនួន ៧៤៥ ទំព័រ រួមទាំងឧបសម្ព័ន្ធផង។

៤. មេធាវីការពារក្តីបានទទួលសំណៅបកប្រែជាភាសាអង់គ្លេស នៃដីកាដំណោះស្រាយរបស់ ស.ច.ស.ជ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩។ សំណៅបកប្រែនេះមានកម្រាស់ ៣៣៩ ទំព័រ រួមទាំងឧបសម្ព័ន្ធផង។

៥. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍

[1] *ដីកាសម្រេចលើកលែងការចោទប្រកាន់* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។

[2] *ដីកាដំណោះស្រាយ* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩,ឯកសារ D382 ។

របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយ[3]។

## II. ច្បាប់ពាក់ព័ន្ធ

៦. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរព [...] កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាក់ទងទៅនឹងសិទ្ធិមនុស្ស។ កិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តម្រូវថា អ.វ.ត.ក អនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានជំនុំជម្រះដោយត្រឹមត្រូវក្នុងកម្រិតអប្បបរមាដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")។ តុលាការបានផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើមាត្រា ១៤(៣)(ខ) ដែលកំណត់ថា យឹម ទិត្យ មានសិទ្ធិទទួលបាន "ពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួនគាត់"។

៧. មាត្រា ៣៥*ថ្មី* នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចែងនៅត្រង់ផ្នែកពាក់ព័ន្ធថា៖

> ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ នៅការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើភាពគ្នា ស្របតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ (ក) ទទួលបានព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន (ខ) មានពេលវេលាដើម្បីរៀបចំខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង [...]។

៨. វិធាន ២១ ចែងថា ច្បាប់ជាធរមាននៅ អ.វ.ត.ក "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងដំណើរការនីតិវិធីប្រកបដោយតម្លាភាព"។

៩. វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ចែងថា៖

> តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើប

[3] *សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/7 និង D382/9 ។

អង្គេត ឬអង្គជំនុំជម្រះអាចៈ

ក) ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់ ឬ

ខ) ទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល។

១០. វិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថាៈ

ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ទៅក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃបានទទួលសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេច ឬដីកា។ ក្នុងកាលៈទេសៈពិសេស រយៈពេលកំណត់នេះអាចពន្យារបាន។

១១. មាត្រា ៥(២) នៃសេចក្តីណែនាំអនុវត្តចែងថា "ឯកសារដាក់នៅអង្គបុរេជំនុំជម្រះ [...] មិនត្រូវលើសពី ៣០ ទំព័រជាភាសាអង់គ្លេស លើកលែងតែមានបញ្ញត្តិចែងផ្ទុយពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក" ឬសេចក្តីណែនាំអនុវត្តនេះ ឬបទបញ្ជាចេញដោយ អ.វ.ត.ក។ អនុលោមតាមមាត្រា ៥(៤) នៃសេចក្តីណែនាំអនុវត្ត តាមការស្នើសុំរបស់ភាគីចូលរួម អ.ប.ជ អាចបង្កើនចំនួនសន្លឹករបស់ឯកសារ នៅក្នុងកាលៈទេសៈពិសេស។

## III. សារណា

១២. មេធាវីការពារក្តី សូមគោរពស្នើសុំឲ្យ អ.ប.ជ ប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមមាត្រា ៥(៤) នៃសេចក្តីណែនាំអនុវត្ត បង្កើនចំនួនទំព័រនៃបណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយ ពីចំនួន ៣០ ទំព័រ រហូតដល់ ចំនួន ១៥០ ទំព័រ ជាភាសាអង់គ្លេស។

១៣. មេធាវីការពារក្តីក៏សូមគោរពស្នើសុំឲ្យ អ.ប.ជ ប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមវិធាន ៣៩(៤) និងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង ពន្យាររយៈពេលកំណត់សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ ពីរយៈពេល ៣០ ថ្ងៃ រហូតដល់ រយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃដែលមេធាវីការពារក្តីបានទទួលសំណៅបកប្រែនៃដីកាដំណោះស្រាយ ទាំងពីរ។

១៤. កាលៈទេសៈពិសេសខាងក្រោម ជាហេតុផលសមស្របក្នុងការយល់ព្រមតាមសំណើសុំទាំងនេះៈ

i. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដោយឡែកពីគ្នា

ii. វិសាលភាព និងភាពស្មុគស្មាញ នៃដីកាដំណោះស្រាយ និង

iii. វិសាលភាពធំធេង និងភាពស្មុគស្មាញដែលជាផលវិបាកនៃបណ្តឹងឧទ្ធរណ៍ដ៏ចាំបាច់នេះ

**ក. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដោយឡែកពីគ្នា**

១៥. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដោយឡែកពីគ្នា ជាបន្ទុកដល់ភាគី ដែលអ្នកធ្វើសេចក្តីព្រាងច្បាប់ និងនីតិវិធី អ.វ.ត.ក ពុំដែលនឹកស្មានដល់។ ភាគីពុំមែនទទួលបានដីកាដំណោះស្រាយតែមួយនោះទេ គឺទទួលបានដីកាដំណោះស្រាយរហូតដល់ទៅពីរ ដែលតម្រូវឲ្យមានការវិភាគលម្អិតលើដីកានីមួយៗ និងទំនាក់ទំនងរវាងដីកាដំណោះស្រាយមួយទៅដីកាដំណោះស្រាយមួយទៀត។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីត្រូវធានាថា លោក យឹម ទិត្យ យល់ទាំងស្រុងអំពីដីកាដំណោះស្រាយទាំងពីរនេះ និងបានទទួលឱកាសពេញលេញ និងត្រឹមត្រូវ ដើម្បីអាចផ្តល់ការណែនាំដល់មេធាវីរបស់ខ្លួនបាន។

១៦. ដើម្បីអាចធ្វើបណ្តឹងឧទ្ធរណ៍បាន មេធាវីការពារក្តីចាំបាច់ត្រូវធ្វើការវិភាគលើអង្គហេតុ និងអង្គច្បាប់នៃដីកាដំណោះស្រាយទាំងពីរ ឲ្យបានពេញលេញ ដែលសរុបរួមគ្នាមានចំនួន ៨២៦ទំព័រជាភាសាអង់គ្លេស បូករួមទាំងឧបសម្ព័ន្ធ។ នៅក្នុងកាលៈទេសៈបែបនេះ មេធាវីការពារក្តីទទួលបន្ទុកធ្ងន់ធ្ងរ និងមិនស្រាកស្រាន្តឡើយ។ មេធាវីការពារក្តីក៏ត្រូវទុកការងាររៀបចំត្រៀមបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ខ្លួនមួយអន្លើសិន ហើយបែរទៅដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ ស.ច.ស.ជ និងដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាដំណោះស្រាយ។

១៧. តាមការកត់សម្គាល់ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ទំនងជាមានការប្រទាំងប្រទិសគ្នាខ្លាំងនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយសារ មិនខុសពីរឿងក្តីផ្សេងទៀត សហព្រះរាជអាជ្ញាបានលើកឡើងទិដ្ឋភាពទឡ្ហីករណ៍ច្របូកច្របល់ស្មុគស្មាញនៅក្នុងបណ្តឹងឧទ្ធរណ៍

ក្នុងសំណុំរឿង ០០៤ ដូច្នេះ វាជាបន្ទុកបន្ថែមលើធនធានរបស់មេធាវីការពារក្ដី[4]។

១៨. ម្យ៉ាងវិញទៀត មេធាវីការពារក្ដីចាំបាច់ត្រូវឆ្លើយតបទៅនឹងភាពចម្លែកផ្នែកនីតិវិធីនៃដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរនេះ ដែលបានបង្កើតជាបន្ទុកបន្ថែមទៀត ពុំមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬសេចក្ដីណែនាំអនុវត្តពាក់ព័ន្ធឡើយ។

១៩. មេធាវីការពារក្ដីត្រូវការពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការវិភាគដីកាដំណោះស្រាយទាំងពីរនៅក្នុងពេលតំណាលគ្នា ដើម្បីខ្លួនអាចត្រៀមការពារក្ដីជូនលោក យឹម ទិត្យ បាន។ មេធាវីការពារក្ដីនឹងមិនអាចមានលទ្ធភាពធ្វើការវិភាគចាំបាច់ និងធ្វើសេចក្ដីព្រាងមូលដ្ឋានចាំបាច់នៃបណ្ដឹងឧទ្ធរណ៍ក្នុងរយៈពេលត្រឹមតែ ៣០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណៅបកប្រែនោះទេ។

**ខ. វិសាលភាព និងភាពស្មុគស្មាញ នៃដីកាដំណោះស្រាយ**

២០. ដីកាដំណោះស្រាយរបស់ ស.ច.ស.អ មានចំនួន ៤៨៧ ទំព័រ បូករួមទាំង ឧបសម្ព័ន្ធ ជាភាសាអង់គ្លេស (៧៤៥ ទំព័រ បូករួមទាំងឧបសម្ព័ន្ធជាភាសាខ្មែរ)។ ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ មានចំនួន ៣៣៩ ទំព័រ បូករួមទាំងឧបសម្ព័ន្ធជាភាសាអង់គ្លេស (៥៦៦ ទំព័រ បូករួមទាំងឧបសម្ព័ន្ធ ជាភាសាខ្មែរ)។ សំអាងហេតុដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយទាំងពីរនេះ រួមបញ្ចូលអង្គហេតុ និងអង្គច្បាប់ដូចខាងក្រោម៖

i. យុត្តាធិការរបស់ អ.វ.ត.ក លើលោក យឹម ទិត្យ

ii. ការកំណត់បទចោទលើឧក្រិដ្ឋកម្មនៅចំពោះមុខ អ.វ.ត.ក

iii. ការកំណត់បទចោទលើទម្រង់នៃការទទួលខុសត្រូវនៅចំពោះមុខ អ.វ.ត.ក

iv. សំអាងហេតុពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើលោក យឹម ទិត្យ។

v. ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក យឹម ទិត្យ

---

[4] *សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D382/4។

២១. ដីកាដំណោះស្រាយបង្ហាញច្បាស់ថាមានកំហុសអង្គច្បាប់ និងអង្គហេតុធ្ងន់ធ្ងរជាច្រើន ដែលកំហុសទាំងអស់នេះ មេធាវីការពារក្តីត្រូវតវ៉ានៅក្នុងបណ្តឹងឧទ្ធរណ៍។ មេធាវីការពារក្តីសូមអះអាងថា ភាពស្មុគ្រស្មាញនៃដីកាដំណោះស្រាយដែលមានចំនួនច្រើនទំព័រ រួមជាមួយនឹងអង្គហេតុពាក់ព័ន្ធគ្នារវាងដីកាដំណោះស្រាយទាំងពីរ តម្រូវឱ្យមានការបង្កើនចំនួនទំព័រ និងពន្យាររយៈពេលកំណត់ ដូចមានចែងនៅក្នុងមាត្រា ៥(៤) នៃសេចក្តីណែនាំអនុវត្ត និងវិធាន ៣៩(៤) និង ៧៥(៣) នៃវិធានផ្ទៃក្នុង។

**គ. វិសាលភាពធំធេង និងភាពស្មុគស្មាញដែលជាផលវិបាកនៃបណ្តឹងឧទ្ធរណ៍ដ៏ចាំបាច់នេះ**

២២. មេធាវីការពារក្តីអះអាងថា ខ្លួននឹងមិនមានលទ្ធភាពបង្ហាញមូលដ្ឋានគាំទ្រឱ្យបានសមស្របចំពោះទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងអង្គហេតុ និងអង្គច្បាប់ស្មុគស្មាញ នៅក្នុងឯកសារត្រឹមតែចំនួន ៣០ ទំព័រ នោះទេ។ មេធាវីការពារក្តី សូមគូសបញ្ជាក់ថា លោក យឹម ទិត្យ មានសិទ្ធិជាសារវ័ន្ត ក្នុងការទទួលបានពេលវេលា និងមធ្យោបាយសមស្រប សម្រាប់ត្រៀមរៀបចំការការពារក្តីរបស់ខ្លួន។

២៣. មេធាវីការពារក្តីក៏សូមកត់សម្គាល់ផងដែរថា អង្គបុរេជំនុំជម្រះបានបង្កើនចំនួនទំព័រ និងពន្យាររយៈពេលកំណត់ ក្រោមកាលៈទេសៈស្រដៀងគ្នានេះ នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក[5]។ សិទ្ធិទទួលបានការប្រព្រឹត្តស្មើភាពគ្នា ក៏ជាហេតុផលសមស្របដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះយល់ព្រមតាមសំណើសុំនេះផងដែរ។

២៤. មេធាវីការពារក្តីសូមអះអាងថា តម្រូវការក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយពីរផ្ទុយគ្នា ដែលមានវិសាលភាព និងភាពស្មុគស្មាញរៀងៗខ្លួន នៅក្នុងបណ្តឹងឧទ្ធរណ៍តែមួយចាំបាច់ត្រូវមានការបង្កើនចំនួនទំព័ររហូតដល់ចំនួន ១៥០ ទំព័រ។

---

[5] សំណុំរឿង ០០៤/២ *សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D360/7។

## IV. **សេចក្ដីសន្និដ្ឋាន**

២៥. យោងតាមវិសាលភាព និងសារៈសំខាន់នៃអង្គហេតុ និងអង្គច្បាប់ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ មេធាវីការពារក្ដីសូមអះអាងថា ការបង្កើនចំនួនទំព័រ និងរយៈពេលកំណត់ដ៏តិចតួចនេះ គឺចាំបាច់ណាស់ ដើម្បីធានានូវសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់លោក យឹម ទិត្យ។ អាស្រ័យហេតុនេះ មេធាវីការពារក្ដីសូមគោរពស្នើសុំឱ្យអង្គបុរេជំនុំជម្រះប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមមាត្រា ៥(៤) នៃសេចក្ដីណែនាំអនុវត្ត និងវិធាន ៣៩(៤) និងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង បង្កើនចំនួនទំព័រសម្រាប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ រហូតដល់ចំនួន ១៥០ ទំព័រ និងពន្យាររយៈពេលកំណត់ រហូតដល់ ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរ។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដូចបានលើកឡើងនៅក្នុងសំណើសុំនេះ មេធាវីការពារក្ដីសូមគោរពស្នើសុំអង្គបុរេជំនុំជម្រះ៖

១. **បង្កើន** ចំនួនទំព័រសម្រាប់បណ្ដឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយ រហូតដល់ចំនួន ១៥០ ទំព័រ។

២. **ពន្យារ** រយៈពេលកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយ រហូតដល់ចំនួន ៤៥ ថ្ងៃ គិតរាប់ចាប់ពីថ្ងៃទទួលបានសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរ។

**ស៊ូ មូស្សេទ្ធី** **Suzana TOMANOVIĆ**

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៩

សហមេធាវីការពារក្ដីលោក យឹម ទិត្យ